**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមហាផ្ទៃ**
**អគ្គស្នងការដ្ឋាននគរបាលជាតិ**

លេខ: ០១០ សណន

ថ្ងៃព្រហស្បតិ៍ ៤រោច ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែសីហា ឆ្នាំ ២០២១

# សេចក្តីណែនាំ

## ស្តីពី

## ការអនុវត្តវិធានការបង្ការ ទប់ស្កាត់ និងបង្ក្រាបសកម្មភាពឆ្លងដែនដោយខុសច្បាប់ និងការលួចលាក់នាំជនបរទេសចេញពីភូមិសាស្ត្របិទខ្ទប់

អនុវត្តតាមសេចក្តីណែនាំលេខ០១៦សណន របស់ក្រសួងមហាផ្ទៃ ចុះថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០២១ ស្តីពីការពង្រឹងវិធានការបង្ការ ទប់ស្កាត់ និងបង្ក្រាបសកម្មភាពឆ្លងដែនដោយខុសច្បាប់ និងការលបលួចនាំជនបរទេសចេញពីភូមិសាស្ត្របិទខ្ទប់ អគ្គស្នងការដ្ឋាននគរបាលជាតិ សូមធ្វើការណែនាំដល់ **ឯកឧត្តម លោកជំទាវអគ្គស្នងការរង លោកប្រធាននាយកដ្ឋាន-អង្គភាព និងលោកស្នងការ នៃស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត** ដូចខាងក្រោម៖

១. ត្រូវកសាងផែនការសកម្មភាព និងចាត់តាំងអនុវត្តជាបន្ទាន់ ដើម្បីបង្ការ ទប់ស្កាត់ និងបង្ក្រាបប្រកបដោយប្រសិទ្ធភាព ទាន់ពេលវេលា នូវរាល់សកម្មភាពនៃការនាំមនុស្សចេញ-ចូលឆ្លងដែនដោយខុសច្បាប់រួមទាំងការលួចលាក់នាំជនបរទេសចេញពីភូមិសាស្ត្របិទខ្ទប់ ឬក៏ចល័តបំពានវិធានការបង្ការ ទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ១៩ និងវិធានការបិទខ្ទប់ភូមិសាស្ត្ររបស់រាជរដ្ឋាភិបាល។

២. ផែនសន្តិសុខ ផែនយុត្តិធម៌ ផែនការពារព្រំដែន និងផែនជំនាញពាក់ព័ន្ធ ត្រូវកសាងផែនការជំនាញសំដៅចូលរួមចំណែកក្នុងការបង្ការ ទប់ស្កាត់ និងបង្ក្រាបសកម្មភាពឆ្លងដែនខុសច្បាប់ និងអំពើរត់ពន្ធមនុស្សប្រកបដោយប្រសិទ្ធភាពខ្ពស់។

៣. លោកស្នងការនៃស្នងការដ្ឋាននគរបាលខេត្តជាប់ព្រំដែន ត្រូវ៖

- ធ្វើសេនាធិការជូនគណៈបញ្ជាការឯកភាពរដ្ឋបាលខេត្ត ក្នុងការដាក់ចេញផែនការសកម្មភាពដើម្បីជំរុញការអនុវត្តវិធានការបង្ការ ទប់ស្កាត់ និងបង្ក្រាបសកម្មភាពឆ្លងដែនដោយខុសច្បាប់ និងការលបលួចនាំជនបរទេសចេញពីភូមិសាស្ត្របិទខ្ទប់ឲ្យទទួលបានលទ្ធផលល្អប្រសើរ

- សហការជាមួយនាយកដ្ឋានជំនាញពាក់ព័ន្ធ និងអាជ្ញាធរមានសមត្ថកិច្ចនៅតាមខ្សែបន្ទាត់ព្រំដែន ដើម្បីពិគ្រោះយោបល់ កំណត់បែងចែកភូមិសាស្ត្រទទួលខុសត្រូវក្នុងការពង្រាយកម្លាំងត្រួតពិនិត្យ ការរៀបចំកម្លាំងឈរជើងបន្ថែមលើគោលដៅក្នុងភូមិសាស្ត្រស្មុគស្មាញ ការរាំងខ្ទប់និងលុបបំបាត់ច្រកក្រៅផ្លូវការ(របៀង) សំដៅលើកកម្ពស់ប្រសិទ្ធភាពក្នុងការបង្ការ ទប់ស្កាត់ និងបង្ក្រាបសកម្មភាពលួចនាំមនុស្សចេញ-ចូលឆ្លងកាត់ព្រំដែនខុសច្បាប់ និងបទល្មើសនានាឆ្លងកាត់ព្រំដែន ព្រមទាំងសហការស្រាវជ្រាវ បង្ក្រាប តាមចាប់មេក្លោងមេខ្យល់ក្នុងប្រទេសយកមកផ្តន្ទាទោសតាមច្បាប់


មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរស័ព្ទ/ទូរពុម្ព: ០២៣ ៧២៧ ៣២៩

- ប្រើប្រាស់វិធានការជំនាញ ប្រមូល និងក្តាប់ឲ្យបានអំពីព័ត៌មានសកម្មភាព និងមុខសញ្ញាដែលលប លួចធ្វើសកម្មភាពនាំមនុស្សចេញ-ចូលឆ្លងកាត់ព្រំដែនដោយខុសច្បាប់ ដើម្បីចាត់វិធានការទាន់ពេលវេលា

- ក្នុងករណីរកឃើញការជ្រៀតចូលរបស់ជនបរទេសដោយខុសច្បាប់ នៅត្រង់ចំណុចណាមួយនៃខ្សែបន្ទាត់ព្រំដែន ត្រូវធ្វើការបណ្តេញចេញនៅហ្នឹងកន្លែងត្រង់ចំណុចនោះ៖ ក៏ប៉ុន្តែក្នុងករណីរកឃើញនៅតាមភូមិសាស្ត្រខាងក្នុងនៃទឹកដីកម្ពុជា ត្រូវឃាត់ខ្លួនបញ្ជូនទៅធ្វើចត្តាឡីស័កស្របតាមវិធានសុខាភិបាល ព្រមទាំងកសាងសំណុំរឿងបញ្ជូនទៅតុលាការវិនិច្ឆ័យទោសតាមច្បាប់។

៤. គ្រប់ស្នងការនៃស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ត្រូវពង្រឹងកិច្ចការសំខាន់ៗមួយចំនួនបន្ថែមទៀតដូចជា៖

- ត្រូវធ្វើសេនាធិការជូនគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី-ខេត្ត ក្នុងការជំរុញការងារផ្សព្វផ្សាយអប់រំប្រជាពលរដ្ឋឲ្យបានយល់ដឹង និងចូលរួមក្នុងការបង្ការ ទប់ស្កាត់សកម្មភាពនាំមនុស្សឆ្លងដែនដោយខុសច្បាប់ និងការលួចនាំជនបរទេសចល័តចេញ-ចូលនៅមូលដ្ឋាន បំពានទៅនឹងវិធានការបង្ការ ទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ-១៩ និងវិធានការបិទខ្ទប់ភូមិសាស្ត្រ

- ការគ្រប់គ្រង ត្រួតពិនិត្យចំពោះការស្នាក់នៅ ការចល័តចេញ-ចូលរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន សំដៅបង្ការ ទប់ស្កាត់ និងបង្ក្រាបនូវរាល់សកម្មភាពបំពានទៅនឹងវិធានការរបស់រាជរដ្ឋាភិបាល ក្នុងការបង្ការ ទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ-១៩ និងវិធានការបិទខ្ទប់ភូមិសាស្ត្រដោយត្រូវ **អនុវត្តវិធានការអប់រំ វិធានការរដ្ឋបាល និងវិធានការច្បាប់** តាមស្ថានភាពជាក់ស្តែង។

- ការត្រួតពិនិត្យការស្នាក់នៅ ការចល័តចេញ-ចូលរបស់ជនបរទេសក្នុងមូលដ្ឋានរបស់ខ្លួនដោយត្រូវអនុវត្តឲ្យបានហ្មត់ចត់តាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ។ ក្នុងករណីរកឃើញមានការចល័ត ឬដឹកជញ្ជូនជនបរទេសគេចវេសពីការធ្វើចត្តាឡីស័ក ឬពីមណ្ឌលចត្តាឡីស័ក ឬក៏បំពានទៅនឹងវិធានការបិទខ្ទប់ភូមិសាស្ត្រ ត្រូវឃាត់ខ្លួនបញ្ជូនទៅធ្វើចត្តាឡីស័ក និងកសាងសំណុំរឿងបញ្ជូនទៅតុលាការ ចាត់ការតាមផ្លូវច្បាប់។

- ត្រូវពង្រឹងការងារនគរបាល និងសហគមន៍ ដោយយកចិត្តទុកដាក់ដឹកនាំ គាំទ្រដល់ប៉ុស្តិ៍នគរបាលរដ្ឋបាល ជាពិសេសត្រូវចុះត្រួតពិនិត្យណែនាំការងារជំនាញ ផ្សព្វផ្សាយគោលការណ៍ថ្មីៗពាក់ព័ន្ធដល់វិធានការបង្ការ ទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ-១៩ និងវិធានការបិទខ្ទប់ភូមិសាស្ត្រ ព្រមទាំងលើកទឹកចិត្តឲ្យមានកិច្ចសហការជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីផ្សព្វផ្សាយអប់រំ កៀរគរប្រជាពលរដ្ឋឲ្យចូលរួមសហការផ្តល់ព័ត៌មានពាក់ព័ន្ធដល់សកម្មភាពនាំមនុស្សឆ្លងដែនខុសច្បាប់ ឬការលួចលាក់នាំជនបរទេសចេញពីភូមិសាស្ត្របិទខ្ទប់។

៥. ឯកឧត្តម លោកជំទាវអគ្គស្នងការរង ដែលត្រូវបានចាត់តាំងឲ្យទទួលខុសត្រូវតាមមុខព្រួញ ទិសភូមិភាគ ត្រូវធ្វើជាសេនាធិការជូនអគ្គស្នងការដ្ឋាននគរបាលជាតិ ក្នុងការចង្អុលដឹកនាំកម្លាំងក្រោមឱវាទដោយត្រូវ៖

- តាមដានត្រួតពិនិត្យជាប្រចាំចំពោះការចាត់តាំងអនុវត្តផែនការសកម្មភាព ក្នុងការបង្ការ ទប់ស្កាត់ និងបង្ក្រាបសកម្មភាពនាំមនុស្សឆ្លងដែនខុសច្បាប់ និងការលួចនាំជនបរទេសចេញពីភូមិសាស្ត្របិទខ្ទប់

- ចង្អុលដឹកនាំជាក់ស្តែងទៅតាមភូមិសាស្ត្រស្ថិតក្នុងដែនសមត្ថកិច្ចដែលបានប្រគល់ជូន ជាពិសេសត្រូវពិនិត្យ ណែនាំជំរុញនូវការអនុវត្តវិធានការនានាក្នុងការទប់ស្កាត់ការនាំមនុស្ស ឬរត់ពន្ធមនុស្សឆ្លងដែនខុសច្បាប់ ដោយមិនត្រូវធ្វើឲ្យប៉ះពាល់ដល់សកម្មភាពប្រកបមុខរបរទទួលទានស្របច្បាប់ប្រចាំថ្ងៃ របស់ប្រជាពលរដ្ឋនៅតាមតំបន់ព្រំដែនឡើយ

- ក្រើនរំលឹក ដាស់តឿនដល់ប្រធាននាយកដ្ឋាន-អង្គភាពពាក់ព័ន្ធ និងគ្រប់ស្នងការ នៃស្នងការដ្ឋានរាជធានី-ខេត្ត ឲ្យធ្វើការណែនាំ អប់រំជាប្រចាំដល់កម្លាំងអនុវត្តច្បាប់ អំពីវិន័យក្រមសីលធម៌ មនសិការវិជ្ជាជីវៈ ដើម្បីជៀសវាងអំពើផ្សំគំនិត បណ្តែតបណ្តោយឲ្យមានការលួចនាំមនុស្សឆ្លងដែនដោយខុសច្បាប់។

៦. ត្រូវមានការសរសើរ ជូនរង្វាន់ លើកទឹកចិត្តដល់អង្គភាព ឬបុគ្គលដែលមានស្នាដៃ ព្រមទាំងត្រូវអនុវត្តវិន័យតឹងរ៉ឹងបំផុតចំពោះអង្គភាព ឬបុគ្គលដែលមានកំហុសឆ្គង ល្មើសទៅនឹងវិន័យកងកម្លាំង។ ករណីធ្ងន់ធ្ងរ ត្រូវចាត់វិធានការច្បាប់យ៉ាងម៉ឺងម៉ាត់បំផុតដោយគ្មានការលើកលែង។

ទទួលបានសេចក្តីណែនាំខាងលើនេះ ស្នើ **ឯកឧត្តម លោកជំទាវអគ្គស្នងការរង លោកប្រធាននាយកដ្ឋាន-អង្គភាពជំនាញពាក់ព័ន្ធ លោកស្នងការនៃស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត** ត្រូវចាត់តាំងអនុវត្តឲ្យមានប្រសិទ្ធភាព ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

**អគ្គស្នងការនគរបាលជាតិ**

**នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត.នេត_សាវឿន**

**<u>ចម្លងជូន៖</u>**

- ឧទ្ទកាល័យ**សម្តេចក្រឡាហោម** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- ឯកឧត្តមរដ្ឋលេខាធិការប្រចាំការ
  "គោរពជូនជ្រាប"
- គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី-ខេត្ត
  "ដើម្បីចូលរួមសហការអនុវត្ត"
- ឯកឧត្តម លោកជំទាវអគ្គស្នងការរង
- លោកប្រធាននាយកដ្ឋាន-អង្គភាពជំនាញ
- លោកស្នងការ នៃស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត
  "ដើម្បីអនុវត្ត"
- ឯកសារកាលប្បវត្តិ